# តើអ្វីទៅ
# ជាការជីករ៉ែ?



# អារម្ភកថា

“តើអ្វីទៅជាការជីកយករ៉ែ?” គឺជាចំណងជើងរបស់សៀវភៅរូបភាពដែលបង្ហាញអំពីការរុករក និង ផលប៉ះពាល់ពីប្រតិបត្តិការរ៉ែ។ សៀវភៅនេះបានចងក្រងសម្រាប់លើកកំពស់ការយល់ដឹងរបស់សហគមន៍។ សៀវភៅនេះបង្ហាញពីការយល់ដឹងជាមូលដ្ឋានពីការជីកយករ៉ែ អ្នកដែលជីកយករ៉ែ ទីកន្លែងជីកយករ៉ែ និង ផលប៉ះពាល់នៃការជីកយករ៉ែ។

## មាតិកា


- តើអ្វីទៅជាការជីករ៉ែ?
- អ្នកណាជាអ្នកជីកយករ៉ែ?
- តើការជីកយករ៉ែត្រូវបានធ្វើឡើងដោយរបៀបណា?
- តើការជីកយករ៉ែត្រូវបានធ្វើនៅទីណា?
- តើការជីកយករ៉ែនឹងមានផលប៉ះពាល់មកលើអ្នកនិងគ្រួសារអ្នកដូចម្តេចខ្លះ?
- តើអ្នកអាចធ្វើអ្វីខ្លះ?



បោះពុម្ព ខែមេសាឆ្នាំ ២០១០



ការិយាល័យ ឌីភីអេ កម្ពុជា

#៦៩Z, ផ្លូវលេខ ៤៥០, ទួលទំពូង II, ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ៥, ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២១៦ ៣៦៩/២១៦ ៤៩៥

ទូរសារ: ០២៣ ២១៧ ៣៤២

គេហទំព័រ: www.dpacam.org

# តើអ្វីទៅជាការជីករ៉ែ?



ការជីករ៉ែគឺជាដំណើរការជីកយករ៉ែចេញពីក្នុងដី។ រ៉ែជាសារធាតុពិសេសដែលកើតចេញពីធម្មជាតិនៅក្នុងថ្មនិងល្បាយនៅក្រោមដី។ រ៉ែភាគច្រើនប្រើរយៈពេលរាប់លានឆ្នាំទើបកកើតឡើង។ នៅពេលដែលរ៉ែត្រូវបានយកចេញពីដី រ៉ែមិនកើតមានវិញឡើយ ។









រ៉ែជាច្រើនត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា
ដូចជា មាស ត្បូង ដែក បុកស៊ីត ស្ពាន់ ធ្យូងថ្ម
និងរ៉ែជាច្រើនទៀត។ រ៉ែដែលជីកយកមកពីក្នុងដី
ត្រូវបានយកទៅធ្វើជាផលិតផលផ្សេងៗ។

# តើអ្នកណាជាអ្នកជីកយករ៉ែ?



រយៈពេលជាយូរណាស់មកហើយ ប្រជាជនកម្ពុជាធ្វើការជីកយករ៉ែជាទ្រង់ទ្រាយតូចៗ។
ធនធានរ៉ែដែលពួកគាត់ជីកបានត្រូវយកមកផលិតជាសម្ភារៈប្រើប្រាស់នៅក្នុងសហគមន៍ ឬលក់យកលុយ ឬដូរយកស្រូវអង្ករ
សត្វជ្រូក ឬគោសម្រាប់ប្រើប្រាស់ រឺបរិភោគក្នុងគ្រួសារ។



នៅក្នុងប្រទេសកម្ពុជា ការជីកយករ៉ែមានទ្រង់ទ្រាយធំកាន់តែកើនឡើង
ដោយសារការធ្វើអាជីវកម្មរ៉ែរបស់ជនជាតិកម្ពុជាដែលមានទ្រព្យសម្បត្តិ និងក្រុមហ៊ុនបរទេសជាច្រើន។

# តើការជីកយករ៉ែត្រូវបានធ្វើឡើងដោយរបៀបណា?



ការជីកយករ៉ែតាមលក្ខណៈធម្មជាតិ រឺគ្រួសារ ត្រូវបានធ្វើឡើងទ្រង់ទ្រាយតូច។
រណ្តៅត្រូវបានជីកដោយប្រើកំលាំង និងឧបករណ៍បែបគ្រួសារ ដើម្បីយករ៉ែ។










ការជីករ៉ែជាទ្រង់ទ្រាយធំត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រមិនមែនបែបប្រពៃណី និងបច្ចេកទេសទំនើប។ វិធីសាស្ត្រទាំងនោះរួមមាន ការប្រើគ្រឿងផ្ទុះ ជាតិគីមី និងប្រើម៉ាស៊ីនធំៗ ឈូសឆាយយករ៉ែពីដី។ ជាតិគីមីពុលត្រូវបានប្រើសម្រាប់លាងថ្មនិងយករ៉ែចេញពីថ្ម។



ការជីកយករ៉ែជាទ្រង់ទ្រាយធំខាងលើនេះត្រូវបានគេហៅថា "រណ្តៅរ៉ែបើកចំហរ" ។
ជាទូទៅ"រណ្តៅនេះ" ត្រូវបានប្រើដើម្បីជីកយករ៉ែដូចជាមាស និងត្បូងថ្ម ។

# តើការជីកយករ៉ែត្រូវបានធ្វើនៅទីណា?



សម្រាប់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ការជីកយករ៉ែត្រូវបានធ្វើឡើងនៅក្នុងដីរបស់ប្រជាជន
នៅសហគមន៍ ជិតផ្ទះ នៅព្រៃភ្នំ បឹង និង អូរ របស់អ្នក។

# តើការជីកយករ៉ែនឹងមានផលប៉ះពាល់មកលើអ្នកនិងគ្រួសារអ្នកដូចម្ដេចខ្លះ?



ការជីកយករ៉ែអាចមានផលប៉ះពាល់មកលើសហគមន៍ និងគ្រួសាររបស់អ្នកតាមហេតុផលផ្សេងៗ។



ការជីកយករ៉ែអាចធ្វើឱ្យអ្នកមិនអាចប្រមូលធនធានមួយចំនួនពីក្នុងព្រៃដូចជា វល្លិផ្តៅ  ជ័រទឹក ឫស្សី ទឹកឃ្មុំ និងសត្វព្រៃតូចៗ។
បើគ្មានធនធានទាំងនេះ ប្រជាជនអាចជួបការលំបាកក្នុងការរកចំណូល ឬចំណីអាហារសម្រាប់គ្រួសារ
របស់ពួកគេឱ្យមានសុខភាពល្អ។




ជាតិគីមីពុលដែលប្រើសម្រាប់ចំរាញ់យករ៉ែអាចបំពុលដល់ប្រភពទឹក ដូចជាទឹកទន្លេ អូរ បឹង និងត្រពាំង។
ការប្រើប្រាស់ជាតិគីមីទាំងនោះមិនបានត្រឹមត្រូវសម្រាប់ចំរាញ់រ៉ែ អាចបំពុលបរិស្ថាន បង្កជំងឺ សម្លាប់មនុស្ស ត្រី គោ ក្របី
និងសត្វព្រៃ។ បើអ្នកដើរកាត់ទឹកមានជាតិពុល ហើយផឹកទឹក ឬមុជទឹកនោះ អ្នកអាចនឹងឈឺ ឬ មានជំងឺសើស្បែក។
បើអ្នកបរិភោគត្រីដែលរស់នៅក្នុងទឹកមានជាតិពុលអ្នកនឹងឈឺដែរ។



ការជីករ៉ែ (ឬការធ្វើអាជីវកម្មរ៉ែ)ក៏អាចធ្វើឱ្យខូចសឹក និងបាក់ដី។




អាចមានការបង្ខំឱ្យចាកចេញពីលំនៅដ្ឋាន។



សត្វក៏អាចទទួលរងផលប៉ះពាល់ដោយសារការជីកយករ៉ែ (ឬការធ្វើអាជីវកម្មរ៉ែ) ដែរ។
សត្វតូចធំដែលរស់នៅក្នុងព្រៃ នៅលើដី និងនៅក្នុងទឹកអាចស្លាប់ពីព្រោះពួកវាបាត់បង់ជម្រក ឬចំណីអាហារ។




គ្រួសារដែលប៉ះពាល់ដោយការជីកយករ៉ែ (ឬការធ្វើអាជីវកម្ម) អាចគិតទៅដល់ពេលមិនទាន់មានការជីកយករ៉ែ នៅក្នុងសហគមន៍របស់ពួកគេ និងការបំផ្លាញធនធានធម្មជាតិ។



# តើអ្នកអាចធ្វើអ្វីបានខ្លះ?

ដើម្បីការពារធនធានធម្មជាតិរបស់អ្នក សមាជិកសហគមន៍ត្រូវតែ:

- បង្កើនការយល់ដឹងអំពីការរុករក និងអាជីវកម្មរ៉ែនៅប្រទេសកម្ពុជា និងផលប៉ះពាល់របស់វាមកលើធនធានធម្មជាតិរបស់អ្នក។
- កសាងបណ្តាញសមាជិកសហគមន៍ និងក្រុមមកពីសហគមន៍ផ្សេងៗ ដើម្បីអ្នកអាចចែករំលែកបទពិសោធន៍ទាក់ទងនឹងផលប៉ះពាល់នៃការជីកយករ៉ែ ។
- ចូលរួមដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន និងការប្រឹក្សាយោបល់ដើម្បីឱ្យមានការយល់ព្រម មានព័ត៌មានគ្រប់គ្រាន់ និងគ្មានការបង្ខំមុនពេលការជីកយករ៉ែ។
- ត្រួតពិនិត្យសកម្មភាពជីករ៉ែ និងប្រមូលព័ត៌មាន និងចងក្រងឯកសារភស្តុតាងទាក់ទងផលប៉ះពាល់មកលើសហគមន៍ និងធនធានធម្មជាតិរបស់អ្នក។
- ចែករំលែកភស្តុតាងជាមួយសហគមន៍ផ្សេងៗ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ។
- តស៊ូមតិដើម្បីការពារធនធានធម្មជាតិ និងសិទ្ធិស្របច្បាប់របស់អ្នក។

► សូមចងចាំថាច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ២០០១ មាត្រាទី៧ ចែងថា

មាត្រា៧

មុននឹងចូលទៅក្នុងដីដែលជាកម្មសិទ្ធិឯកជន ដើម្បីធ្វើការស្វែងរកនិងជីកយករ៉ែសម្បទានិកត្រូវមានការព្រមព្រៀងជាលាលក្ខណ៍អក្សរជាមួយម្ចាស់កម្មសិទ្ធិដីធ្លីស្តីពីការមិនជ្រៀតជ្រែកមិនប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងការងារ ព្រមទាំងធ្វើការទូទាត់សងលើការខូចខាតដែលកើតមាននៅលើផ្ទៃដីដែលបណ្តាលមកពីសកម្មភាពប្រតិបត្តិការធនធានរ៉ែ។

DPA

DEVELOPMENT AND PARTNERSHIP IN ACTION

CAFOD Just one world

Caritas AOTEAROA NEW ZEALAND

CANADIAN CATHOLIC ORGANIZATION FOR Development and Peace

christian aid JOINT PROGRAMME

សហភាពអឺរ៉ុប

FUNDACIÓN ETEA PARA EL DESARROLLO Y LA COOPERACIÓN

Manos Unidas CAMPAÑA CONTRA EL HAMBRE

MISEREOR DAS HILFSWERK

NORWEGIAN PEOPLE'S AID

Oxfam

SCIAF Scotland's aid agency

TROCAIRE Working for a Just World